**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១៧/១២/២០០៨ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨

## ជម្រាបមក

**លោក ថាច់ ឃុនសារិន** តំណាងគណបក្ស សម រង្ស៊ី
ប្រធានក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្ដឹងរបស់លោក ថាច់ ឃុនសារិន ប្ដឹងបដិសេធលទ្ធផលនៃការបោះឆ្នោតសង្កាត់និរោធ និងសុំឱ្យមានការរៀបចំការបោះឆ្នោតឡើងវិញ

**យោង** : បណ្ដឹងគ្មានលេខ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៨ របស់លោក ថាច់ ឃុនសារិន តំណាងគណបក្ស សម រង្ស៊ី

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោក ថាច់ ឃុនសារិន ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្ដឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្ដឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្ដឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និងមាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**
**ឯក សំអុល**